# ១.សុវត្ថិភាពក្នុងការប្រើប្រាស់គោយន្ត

ដើម្បីការពារទុកជាមុននូវគ្រោះថ្នាក់ទាំងឡាយដែលអាចកើតឡើងជាយថាហេតុ  អ្នកប្រើប្រាស់គ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្មត្រូវមានការប្រុងប្រយ័ត្នគ្រប់ពេលវេលាក្នុងពេលអនុវត្តការងារ។

## ១.១ មុនពេលបញ្ឆេះគោយន្ត

- ត្រូវត្រួតពិនិត្យកិច្ចថែទាំបច្ចេកទេសប្រចាំថ្ងៃ
- ត្រូវត្រួតពិនិត្យស្ថានភាពចង្កឹះលេខឲ្យស្ថិតនៅក្នុងទីតាំង ឯករាជ្យ (ណឺត)
- ត្រូវត្រួតពិនិត្យអំប្រាយ៉ា(ស្ថានភាពផ្តាច់)
- ត្រួតពិនិត្យសម្ពាធកង់ (១.៨-២.0 kgf/cm²)
- ដាក់ចន្ទល់គោយន្ត
- ត្រូវត្រួតពិនិត្យប្រព័ន្ធចង្កូត



ចន្ទល់

## ១.២ ពេលបញ្ឆេះគោយន្ត

– ត្រូវដាក់ដៃបញ្ឆាប្រេង (ហ្គារ) ក្នុងស្ថានភាពមធ្យម



– ពេលបញ្ឆេះចលករមិនត្រូវដាក់ដៃរវៃឲ្យនៅចំណុចខាងលើទេ ពីព្រោះនាំឲ្យមានគ្រោះថ្នាក់



– ពេលបញ្ឆេះគោយន្តត្រូវដាក់ដៃរវៃឲ្យនៅត្រង់ចំណុចក្រោម



- ហាមបង់កក្រម៉ានៅពេលបញ្ឆេះចលករ
- ត្រូវពាក់មួកការពារ(បើអាចធ្វើបាន)

## ១-៣ ពេលចលករធ្វើការ

- ស្តាប់ស្នូរប្លែកក្នុងចលករ
- ពិនិត្យការលេចជ្រាបគ្រប់កន្លែង
- ត្រូវលើកចន្ទល់
- បញ្ចោចង្កឹះលេខអំប្រាយ៉ាដោយសន្សឹមៗ
- ពេលបើកថយក្រោយត្រូវប្រើលេខល្បឿនយឺតនិងបញ្ចោចង្កឹះអំប្រាយ៉ាសន្សឹមៗ
- ពេលបើកបរចុះផ្លូវចំណោតត្រូវប្រើលេខល្បឿនយឺត ចៀសវាងការចាប់ហ្វ្រាំងចង្កូតបង្វិ